ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា







# សៀវភៅអមនៃឯកសារការអប់រំបរិយាបន្ន

សម្រាប់គ្រូឧទ្ទេស (TOTs)

ឆ្នាំ២០១៧

# មាតិកា

អារម្ភកថា........................................................................................... ៣
ប្រធានបទទី ១៖ របៀបរៀនរបស់មនុស្សពេញវ័យ ................................. ៤
ប្រធានបទទី ២៖ ការអនុវត្តវិធីបង្រៀនការអប់រំបរិយាបន្ន ................. ១៦
ប្រធានបទទី៣៖ ការប្រើប្រាស់វិធីបង្រៀនការអប់រំបរិយាបន្នដោយផ្តោតសំខាន់លើការអនុវត្តជាក់ស្តែង .................................................... ២០
សន្និដ្ឋាន.............................................................................................. ២៣
ឯកសារយោង៖ ...................................................................................... ២៤

# អារម្ភកថា

ក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយនឹងគណៈកម្មការបច្ចេកទេស មកពីនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានអប់រំពិសេស គ្រូឧទ្ទេសមកពីសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត (PTTCs) អង្គការយូនីសេហ្វ អង្គការគ្រួសារថ្មី និងអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ការអប់រំដល់ជនពិការបានបង្ហាញយ៉ាងច្បាស់ថា គ្រូឧទ្ទេសមួយចំនួនមិនបានបង្រៀនកុមារពិការ ឬមិនបានរៀនអំពីវិធីបង្រៀនការអប់រំបរិយាបន្ន ។

គោលបំណងនៃសៀវភៅអមនេះ គឺសម្រាប់ជួយគ្រូឧទ្ទេសយល់ដឹងពីរបៀបរៀនរបស់មនុស្សពេញវ័យ ដើម្បីធ្វើឱ្យការបង្រៀនមានលក្ខណៈបរិយាបន្ន ។ តាមរយៈការយល់ដឹងរបស់គ្រូឧទ្ទេសធ្វើឱ្យគរុសិស្សកាន់តែមានភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់នូវវិធីបង្រៀនដោយខ្លួនឯងនៅពេលចាប់ផ្តើមអាជីពជាគ្រូបង្រៀន។

គ្រូឧទ្ទេសទាំងអស់ត្រូវអានព័ត៌មានក្នុងសៀវភៅនេះ ហើយបំពេញនូវលំហាត់ទាំងអស់ដែលបានដាក់ឱ្យបំពេញ មុនពេលចាប់ផ្តើមបង្រៀនឯកសារការអប់រំបរិយាបន្ន ។

**និពន្ធដោយ** Kiran Dattani Pitt **និង** Sandrine Bohan-Jacquot

## ប្រធានបទទី ១៖ របៀបរៀនរបស់មនុស្សពេញវ័យ

"...ការសិក្សាគឺជាដំណើរការនៃការចង់ដឹង ដែលក្នុងនោះអ្នកសិក្សាមានតួនាទីយ៉ាងសកម្ម ហើយតួនាទីរបស់គ្រូគឺណែនាំ សម្របសម្រួល និងជាធនធានសម្រាប់ការចង់ដឹងនោះ"

ដោយ Malcolm Knowles[1]

**ការឆ្លុះបញ្ចាំង (reflection)**

ចូរលើកយកបទពិសោធដែលបានសិក្សាថ្មីៗដែលមានលក្ខណៈជោគជ័យសម្រាប់អ្នក ហើយគិតអំពីមូលហេតុអ្វីដែលធ្វើឱ្យបទពិសោធនោះមានភាពលេចធ្លោ និងធ្វើឱ្យអ្នកមានការចងចាំមិនភ្លេច ។

នៅលើក្តារខៀនសរសេរថា *"គោលការណ៍នៃរបៀបរៀនរបស់មនុស្សពេញវ័យ"* រួចហើយសួរអ្នកចូលរួមអំពីអ្វីដែលពួកគេគិតអំពីគោលការណ៍នេះ ។ ចូរសួរអ្នកចូលរួមនូវសំណួរមួយហើយមួយទៀតរហូតដល់ពួកគេអស់គំនិតក្នុងការឆ្លើយ ។

តើគោលការណ៍[2] ដែលអ្នកបានគិតរួមបញ្ចូលនូវចំណុចទាំងនេះដែរឬទេ?៖

- តើអ្នកចូលរួមពេញលេញក្នុងការរៀននៅទីណា?
- តើគ្រូរីករាយ និងមានចំណាប់ចំណូលចិត្តចំពោះមុខវិជ្ជាដែលគាត់បង្រៀនដែរឬទេ?
- តើមតិ និងទស្សនៈរបស់អ្នក ត្រូវបានគេយកចិត្តទុកដាក់ស្តាប់ដែរឬទេ?
- តើបរិយាកាសមានសុវត្ថិភាពសម្រាប់អ្នកក្នុងការបញ្ចេញគំនិតដែរឬទេ?
- តើអ្នកមានឱកាសក្នុងការអនុវត្តនូវអ្វីដែលអ្នកកំពុងរៀនដែរឬទេ?
- តើអ្នកអាចមានលទ្ធភាពធ្វើការសន្ទនាដោយស្មោះត្រង់ និងបើកចំហជាមួយនឹងមិត្តរួមថ្នាក់ និងគ្រូដែរឬទេ? ។ល។

---

[1] Malcom Knowles (2010) "ដំណើរការនៃការសិក្សារបស់មនុស្សពេញវ័យ៖ គរុកោសល្យ និងវិធីបង្រៀនមនុសពេញវ័យ" ប្រភពពីអ៊ីនធើណេតក្នុង Taylor and Francis

[2] ដកស្រង់ចេញពី (ប្រភពពីអ៊ីនធើណេតដែលមិនមានកាលបរិច្ឆេទ) "តើអ្វីទៅដែលធ្វើឱ្យការសិក្សារបស់មនុស្សពេញវ័យមានប្រសិទ្ធភាព" ធនធានពីមុខវិជ្ជាខ្នាតតូចរបស់គ្រូបង្រៀន (Mini-course instructor)

ចូរអាននូវចំណុចទាំងនេះ៖

## គោលការណ៍ទាំង១២អំពីរបៀបរៀនរបស់មនុស្សពេញវ័យ[3]

១. **ការវាយតម្លៃពីតម្រូវការ** (អ្នកសិក្សាចូលរួមជ្រើសរើសមេរៀននិងប្រាប់អំពីអ្វីដែលចង់រៀន) ។

២. **សុវត្ថិភាព** (បរិយាកាស និងដំណើរការសម្រាប់គ្រូនិងសិស្ស)

៣. **ទំនាក់ទំនងជិតស្និទ្ធ** (រវាងគ្រូ និងសិស្ស)

៤. **លំដាប់លំដោយ និងការពង្រឹងការរៀន** (ពីគំនិតសាមញ្ញឆ្ពោះទៅរកភាពស្មុគស្មាញ និងក្រុមគាំទ្រចំពោះកិច្ចខិតខំប្រឹងប្រែងរៀនជាបុគ្គល)

៥. **ការអនុវត្ត** (សកម្មភាពរៀនដោយមានការឆ្លុះបញ្ចាំង)

៦. **ការគោរព** (អ្នកសិក្សាដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្ត)

៧. **គំនិត អារម្មណ៍ និងសកម្មភាព** (ខួរក្បាល បេះដូង ដៃ ជើង និងដងខ្លួន )

៨. **ភាពឆ្លើយតបភ្លាមៗ** (អាស្រ័យការមើលឃើញថាវាមានប្រយោជន៍)

៩. **តួនាទីច្បាស់លាស់** (ត្រូវបានកំណត់យ៉ាងច្បាស់លាស់សម្រាប់គ្រូនិងសិស្ស ដែលគ្រូជាអ្នកសម្របសម្រួល មិនមែនជា"សាស្ត្រាចារ្យ" មានចំណេះដឹងទាំងអស់ឡើយ)

១០. **ការងារក្រុម** (ដោយប្រើប្រាស់ក្រុមតូចក្នុងការសន្ទនាជាមួយគ្នា មិនត្រឹមតែសន្ទនាជាមួយនឹងគ្រូឡើយ)

១១. **ការជំរុញឱ្យមានការចូលរួម** (រវាងសិស្សជាមួយនឹងអ្វីដែលគេកំពុងតែសិក្សាដើម្បីយល់ច្បាស់ និងអាចអនុវត្តបាន)

១២. **គណនេយ្យភាព** (តើអ្នករៀនដឹងថាពួកគេកំពុងរៀនអ្វីដែរឬទេ? ការរៀបចំផែនការបង្រៀន មានគណនេយ្យភាពចំពោះអ្នករៀន គ្រូ និងអ្នកសិក្សាផ្សេងទៀតដែរឬទេ?)

[3] ដកស្រង់ចេញពីការរៀនស្តាប់ រៀនបង្រៀនដោយ Jane Vella (2002) ជំពូក ១. Jossey-Bass, San Francisco, USA.

*គោលការណ៍១២ ស្តីអំពីរបៀបរៀនរបស់មនុស្សពេញវ័យដោយមានការពន្យល់បន្ថែម (ដកស្រង់ចេញពីJane Vella)*[4]

**គោលការណ៍ទី ១៖ ការវាយតម្លៃពីតម្រូវការ**

តើយើងរកឃើញនូវអ្វីដែលអ្នកសិក្សាបានដឹងរួចហើយតាមវិធីណា? ហើយតើចំណុចណាខ្លះដែលយើងត្រូវយកមកធ្វើការពិចារណា នៅពេលដែលរៀបចំមេរៀនឬសកម្មភាពរៀន?

សម្រាប់គ្រូឧទ្ទេស វាមានសារៈសំខាន់ក្នុងការស្គាល់អ្នកសិក្សា ឬគរុសិស្សនៅក្នុងការបណ្តុះបណ្តាល។ ការស្តាប់ ការស្វែងយល់អំពីគោលបំណង និងសេចក្តីត្រូវការរបស់អ្នកសិក្សា រួចធ្វើផែនការបង្រៀនទៅតាមនោះត្រូវបានគាំទ្រដោយ Paolo Friere[5] ។ នៅពេលគរុសិស្សជួបគ្រូឧទ្ទេសដែលមានចំណាប់អារម្មណ៍ចំពោះតម្រូវការក្នុងការសិក្សា និងបទពិសោធជីវិតរបស់ពួកគេបានលើកទឹកចិត្តដល់ពួកគេក្នុងការរៀន និងចូលរួមក្នុងដំណើរការនៃការសិក្សា។ ដូចបានពន្យល់ដោយ Wheatley[6] "*ការរកឃើញនូវអ្វីដែលមានអត្ថន័យចំពោះមនុស្សម្នាក់ មនុស្សមួយក្រុម ឬអង្គការមួយ គឺជាកិច្ចការចាំបាច់ដំបូងបង្អស់*"។

ការវាយតម្លៃពីតម្រូវការមិនមែនជាមុខវិជ្ជាដែលបានកំណត់នៅក្នុងកម្មវិធីសិក្សាឡើយ ប៉ុន្តែបានធ្វើឱ្យគ្រូឧទ្ទេសដឹង អំពីការរៀបចំនូវសកម្មភាពដែលត្រូវអនុវត្តក្នុងការបង្រៀនមេរៀន ។

**គោលកាណ៍ទី ២៖ សុវត្ថិភាព**

ការបង្កើតនូវសុវត្ថិភាពនៅក្នុងថ្នាក់រៀនបានជួយដោះស្រាយបញ្ហាជាច្រើន ដែលគ្រូឧទ្ទេសត្រូវយកមកពិចារណា ការធ្វើដូច្នេះមិនត្រឹមតែបង្កលទ្ធភាពដល់អ្នកសិក្សាមានអារម្មណ៍ថាមានសុវត្ថិភាព ប៉ុន្តែថែមទាំងធ្វើឱ្យពួកគេចូលរួមជជែកវែកញែកក្នុងបរិយាកាសមានសុវត្ថិភាពផងដែរ។ ការសិក្សាកើតឡើងនៅពេលដែលអ្នកសិក្សាត្រូវបានអនុញ្ញាតឱ្យពិភាក្សាដេញដោលនៅក្នុងបរិយាកាសដែលមានសុវត្ថិភាព និងផ្តល់លទ្ធភាពក្នុងការអនុវត្ត ។

កត្តាទាំងឡាយដែលអាចជួយបញ្ហានេះរួមមាន៖ ការបង្កើតឱ្យមាននូវបរិយាកាសស្វាគមន៍សម្រាប់អ្នកសិក្សា ការជឿជាក់លើការរៀបចំនូវកម្មវិធីសិក្សា អ្នកសិក្សាអាចបញ្ចេញសំឡេង ឬមតិរបស់គេបាន អ្នកសិក្សាអាចនិយាយថាគេមិនដឹងអំពីអ្វី ដោយមិនប្រឈមមុខនឹងការចោទប្រកាន់ ។

---

[4] ដូចចំណុច៣ ខាងលើ

[5] Paolo Friere (1972) "គរុកោសល្យសម្រាប់អ្នកដែលត្រូវបានគេជិះជាន់" New York: Herder and Herder.

[6] Margaret Wheatley (1999) ការដឹកនាំ និងវិទ្យាសាស្ត្រថ្មី San Francisco: Barrett-Koehler ទំព័រ ១៤៩

**គោលការណ៍ទី ៣៖ ទំនាក់ទំនងជិតស្និទ្ធ**

ទំនាក់ទំនងជិតស្និទ្ធនៅក្នុងការសិក្សាពាក់ព័ន្ធនឹងការគោរព ទំនាក់ទំនងដោយចំហ ការស្តាប់ មានសុវត្ថិភាព និងសុភាពរាបសា។ គ្រូឧទ្ទេសបង្ហាញថា ពួកគេមានភាពងាយស្រួលក្នុងការជួបជាមួយសិស្ស មានការសន្ទនាជាមួយគ្នា អ្នកសិក្សាមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការសួរសំណួរ ត្រូវបានគេយកចិត្តទុកដាក់ស្តាប់ និងត្រូវបានគេគោរព វាបង្កើតបាននូវទំនាក់ទំនងជិតស្និទ្ធរវាងអ្នកសិក្សា និងគ្រូឧទ្ទេស។

**គោលការណ៍ទី៤៖ លំដាប់លំដោយ និងការពង្រឹងការរៀន**

លំដាប់លំដោយ និងការពង្រឹងការរៀនមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ការសិក្សារបស់មនុស្សពេញវ័យ ហើយគ្រូឧទ្ទេសណាម្នាក់ដែលមិនបានធ្វើដូច្នេះនឹងប្រឈមចំពោះភាពបរាជ័យក្នុងការបង្រៀន។

លំដាប់លំដោយ សំដៅការរៀបចំខ្លឹមសារចំណេះដឹង បំណិន និងឥរិយាបថ ដែលចាប់ផ្តើមចេញពីភាពងាយស្រួលទៅលំបាក និងពីកិច្ចការជាក្រុមទៅជាកិច្ចការបុគ្គល។ កិច្ចការដែលដាក់ឱ្យបំពេញដោយគ្រូឧទ្ទេសត្រូវការចាប់ផ្តើមពីភាពងាយស្រួលទៅលំបាក ហើយប្រសិនបើកិច្ចការដែលដាក់ឱ្យបំពេញមានភាពលំបាកពេក គ្រូឧទ្ទេសត្រូវកែសម្រួល។ ប្រសិនបើមិនកែសម្រួលទេនោះ វានឹងធ្វើឱ្យអ្នកសិក្សាមានអារម្មណ៍ថា ខ្វះខាត ច្របូកច្របល់ ហើយអារម្មណ៍នៃសុវត្ថិភាពដែលបានបង្កើតឡើងត្រូវបាត់បង់ទៅវិញ។ ក្នុងការកែសម្រួលកិច្ចការ គ្រូឧទ្ទេសបង្ហាញនូវចិត្តសុភាពរាបសា ហើយថាពួកគេមិនសុទ្ធតែនិយាយត្រូវគ្រប់ពេលវេលានោះទេ នេះប្រហែលជាមានការលំបាកនៅក្នុងបរិបទប្រទេសកម្ពុជា ប៉ុន្តែនេះជាអ្វីដែលគ្រូឧទ្ទេសគួរតែលើកទឹកចិត្តខ្លួនឯងក្នុងការធ្វើដូច្នេះ។

ការពង្រឹងការរៀនមានន័យថា ការរំលឹកឡើងវិញនូវព័ត៌មាន បំណិន និងឥរិយាបថតាមរយៈសកម្មភាពខុសៗគ្នាជាច្រើន ដែលគួរឱ្យចាប់អារម្មណ៍និងសប្បាយរីករាយ ។

**គោលការណ៍ទី ៥៖ ការអនុវត្ត (Praxis)**

Praxis ជាពាក្យក្រិចមានន័យថា "សកម្មភាពដោយមានការឆ្លុះបញ្ចាំង" ហើយគ្រូឧទ្ទេស ទាំងឡាយអាចណែនាំឱ្យយកមកប្រើប្រាស់នៅក្នុងការរៀបចំមេរៀន។ ចំពោះប្រសិទ្ធភាពគឺនាំមកនូវលទ្ធផលដែលអ្នកសិក្សាអាចរៀនចំណេះដឹងថ្មី បំណិន និងឥរិយាបថ ដែលពួកគេនឹងអាចយកទៅអនុវត្ត។ ពេលដែលគេយកទៅអនុវត្តនូវអ្វីដែលគេបានរៀន ពួកគេឆ្លុះបញ្ចាំងនូវសកម្មភាពដែលសម្តែងឡើង និងរិះរកវិធីផ្សេងៗ ដែលផ្តល់នូវដំណោះស្រាយល្អបំផុត។

Praxis គឺជាដំណើរការដែលកំពុងបន្ត ទាំងគ្រូឧទ្ទេស និងគរុសិស្សនឹងទទួលបានអត្ថប្រយោជន៍យ៉ាងជ្រាលជ្រៅ ប្រសិនបើគេយកវាមកប្រើប្រាស់ជាមធ្យោបាយក្នុងការបំពេញការងារ។

**គោលការណ៍ទី ៦៖ ការគោរព (អ្នកសិក្សាដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្ត)**

ក្នុងការរៀបចំមេរៀន អ្នកសិក្សាត្រូវការដឹងថាពួកគេអាចធ្វើសេចក្តីសម្រេចចិត្តសម្រាប់ខ្លួនគេ នូវអ្វីដែលបានកើតមានឡើងចំពោះពួកគេក្នុងព្រឹត្តិការណ៍នៃការសិក្សា។ វាអាចត្រូវសម្រេចបានដោយគ្រូឧទ្ទេសសួរសំណួរយ៉ាងសាមញ្ញមួយថា "តើមានអ្វីផ្សេងទៀតទេ ដែលអ្នកមានអារម្មណ៍ថាចង់រៀន?" សំណួរនេះធ្វើឱ្យអត្ថន័យនៃមេរៀនមានភាពជាប្រព័ន្ធបើកចំហ ហើយគ្រូឧទ្ទេសត្រូវធ្វើការកែសម្រួលបន្ថែម និងកែប្រែនូវសកម្មភាពក្នុងប្រធានបទ ឬមេរៀន។

**គោលការណ៍ទី ៧៖ គំនិត អារម្មណ៍ និងសកម្មភាព**

គោលការណ៍នេះជារឿយៗមិនត្រូវបានយកចិត្តទុកដាក់ ប៉ុន្តែវាជាគោលការណ៍សំខាន់មួយ ដោយសារតែវាយកចិត្តទុកដាក់ទៅលើទិដ្ឋភាពនៃបញ្ញា(ចិត្ត) មនោសញ្ចេតនា (ផ្លូវអារម្មណ៍) និងរូបារម្មណ៍ (សាច់ដុំ និងចលនា) នៃការសិក្សារបស់មនុស្សពេញវ័យ។ បើមិនដូច្នេះទេអ្នកសិក្សានឹងប្រឈមមុខទៅនឹងទំហំយ៉ាងធំធេងនៃព័ត៌មានធ្វើឱ្យមានការលំបាកក្នុងការចងចាំ។

ម្យ៉ាងទៀត ការយកចិត្តទុកដាក់ទៅលើមនុស្សទាំងមូល ផ្តោតទៅលើគំនិត អារម្មណ៍ និងសកម្មភាពរបស់ពួកគេ មានន័យថាគ្រូឧទ្ទេសមិនចាត់ទុកថាសិស្សទាំងឡាយជាម៉ាស៊ីន ប៉ុន្តែជាមនុស្សដែលមានការរីកចម្រើន ។

**គោលការណ៍ទី ៨៖ ភាពឆ្លើយតបភ្លាមៗ**

អ្វីដែលជួយឱ្យមនុស្សពេញវ័យរៀនបានប្រសើរជាងមុនគឺ នៅពេលដែលពួកគេអាចប្រើចំណេះដឹង ជំនាញ និងឥរិយាបថដែលពួកគេបានរៀនតាមរយៈការអនុវត្ត។ ដូចនេះមិនមានន័យថាវាបានធ្វើឡើងភ្លាមៗទេ ប៉ុន្តែវាជាទស្សនៈនៃការទទួលយកភាពឆ្លើយតបភ្លាមៗ ដែលត្រូវបានគេមើលឃើញ។ នៅពេលដែលអ្នកសិក្សាដឹងអំពីលំដាប់លំដោយនៃការសិក្សា ពួកគេអាចដឹងពីគោលដៅដែលត្រូវធ្វើដំណើរឆ្ពោះទៅ និងឱកាសក្នុងការប្រើចំណេះដឹងរបស់គេទៅក្នុងការអនុវត្ត។ វាគឺជាគោលការណ៍យ៉ាងសំខាន់បំផុតសម្រាប់គ្រូឧទ្ទេសនិងគរុសិស្ស ដោយសារតែការអនុវត្តនូវអ្វីដែលគេរៀន ផ្តល់នូវជំនឿចិត្តក្នុងការរៀនសូត្រ។ ភាពឆ្លើយតបភ្លាមៗធ្វើឱ្យពួកគេមានការប្តេជ្ញាចិត្ត ក្នុងការបន្តការសិក្សាទៅមុខទៀត។

**គោលការណ៍ទី ៩៖ តួនាទីច្បាស់លាស់**

គោលការណ៍នេះបង្ហាញពីភាពច្បាស់លាស់នៃតួនាទីនៅក្នុងកិច្ចសន្ទនារវាងអ្នកសិក្សា និងគ្រូឧទ្ទេស។ **Jane Vella** អធិប្បាយចំណុចនេះយ៉ាងច្បាស់លាស់នៅក្នុងកិច្ចសន្ទនាដែលគាត់បានធ្វើឡើងជាមួយនឹង **Paolo Friere**។

គ្រូប្រហែលជាអាចលំបាកក្នុងការសន្ទនាជាមួយនឹងអ្នកសិក្សាពេញវ័យ ប៉ុន្តែប្រសិនបើអ្នកសិក្សាមើលឃើញថាគ្រូជា "សាស្ត្រាចារ្យ" ពួកគេមិនហ៊ានបង្ហាញភាពមិនយល់ស្រប មិនហ៊ានសួរ មិនហ៊ានជជែកវែកញែកជាមួយគ្រូ ដូច្នេះកិច្ចសន្ទនានេះមិនកើតមានឡើងបានឡើយ។ សិស្សពេញវ័យត្រូវការពង្រឹងភាពស្មើគ្នារបស់មនុស្សរវាងគ្រូ និងសិស្ស និងក្នុងចំណោមសិស្សទាំងឡាយ។ វាត្រូវការពេលវេលាសម្រាប់មនុស្សពេញវ័យក្នុងការមើលឃើញអំពីខ្លួនគេ និងតួនាទីថ្មីជាគ្រូ។

ប្រសិនបើមនុស្សពេញវ័យមានបទពិសោធច្រើនក្នុងប្រធានបទដែលកំពុងតែសិក្សា គ្រូឧទ្ទេសអាចសុំឱ្យអ្នកសិក្សាចែករំលែកបទពិសោធនោះ។ ការធ្វើដូច្នេះអ្នកសិក្សាមានអារម្មណ៍ថា គេមានតម្លៃ និងផ្តល់ដល់អ្នកសិក្សាផ្សេងទៀតនៅក្នុងថ្នាក់រៀននូវជំនឿចិត្តផងដែរ។

**គោលការណ៍ទី ១០៖ ការងារជាក្រុម**

ការងារជាក្រុមត្រូវផ្តោតលើគោលការណ៍ និងដំណើរការ។ សមាជិកក្រុមផ្តល់នូវគុណភាពនៃសុវត្ថិភាព ដែលមានប្រសិទ្ធភាពនិងមានអត្ថប្រយោជន៍។ វាក៏មានន័យថាក្រុមការងារទទួលខុសត្រូវរួមគ្នាក្នុងការបំពេញការងារ។ អ្នកសិក្សាក៏ត្រូវបានអញ្ជើញឱ្យធ្វើការជាមួយនឹងមិត្តភក្តិ ប្រសិនបើអាចជួយដល់ពួកគេក្នុងការដោះស្រាយបញ្ហាលំបាក

ដោយសុវត្ថិភាព ការធ្វើរបៀបនេះគ្រូឧទ្ទេសអាចបង្កើតបាននូវស្ថានភាពឈ្នះឈ្នះ។ ដូចនេះមានន័យផងដែរថាអ្នកសិក្សាត្រូវបានរាប់បញ្ចូលដោយមិនបានទុកចោល ដោយសារតែបានផ្តល់ឱ្យនូវកិច្ចការជាក្រុម នៅពេលដែលពួកគេមិនអាចមានអារម្មណ៍ថាមានលទ្ធភាពក្នុងការបញ្ចេញយោបល់ និងទស្សនៈដែលត្រូវទទួលយកក្នុងក្រុម ។

នៅក្នុងក្រុម ការសិក្សាត្រូវបានពង្រីកនៅពេលដែលមិត្តរួមក្រុមមានបទពិសោធជីវិតស្រដៀងគ្នា ជជែកវែកញែកជាមួយគ្នាតាមរបៀបដែលគ្រូមិនអាចធ្វើបាន។ មិត្តរួមក្រុមក៏ជួយសមាជិកក្រុមណាម្នាក់ ដែលមានការលំបាកដោះស្រាយជាមួយនឹងគំនិតពិបាកៗ ដោយបង្កើតជាសំណាញ់សុវត្ថិភាព (safety net) ដែលអនុញ្ញាតឱ្យអ្នកសិក្សារូបនោះអាចសួរសំណួរបាន ។

ការងារជាក្រុមក៏បង្កើតឡើងផងដែរនូវការប្រកួតប្រជែងរវាងក្រុមផ្សេងទៀត ធ្វើដូច្នេះនឹងនាំមកនូវថាមពលច្រើនជាងមុននៅក្នុងដំណើរការនៃការសិក្សា ។

**គោលការណ៍ទី ១១៖ ការជំរុញឱ្យមានការចូលរួម**

គោលការណ៍នេះស្តីអំពីអ្នកសិក្សាដែលជាអ្នកចូលរួមយ៉ាងសកម្ម (active participant) នៅក្នុងការសិក្សារបស់គេ ជាជាងអ្នកសិក្សាអកម្មបែបយន្តការ (mechanistic passive learner) ។ នៅពេលដែលអ្នកសិក្សាសកម្មមានការចូលរួមយ៉ាងជ្រាលជ្រៅក្នុងការរៀន ហើយប្រសិនបើពួកគេមានការរីករាយនឹងបទពិសោធនៃការរៀនវានឹងក្លាយជាការរៀនតាមរយៈមធ្យោបាយបែបច្នៃប្រឌិត ។

**គោលការណ៍ទី ១២៖ គណនេយ្យភាព**

គណនេយ្យភាពនៅក្នុងបរិបទនេះដំណើរការតាមរបៀបបីយ៉ាងគឺ ពីគ្រូឧទ្ទេសទៅកាន់អ្នកសិក្សា ពីអ្នកសិក្សាទៅកាន់អ្នកសិក្សាខ្លួនឯង និងពីអ្នកសិក្សាម្នាក់ទៅកាន់អ្នកសិក្សាផ្សេងទៀត។ គ្រូឧទ្ទេសត្រូវមានគណនេយ្យភាពចំពោះអ្នកសិក្សាតាមរយៈការរៀបចំនូវព្រឹត្តិការណ៍សិក្សាដែលបង្ហាញថាអ្នកសិក្សាបានរៀននូវអ្វីដែលពួកគេត្រូវរៀន។ ពួកគេបង្ហាញអំពីអ្វីដែលគេបានរៀនតាមរយៈការអនុវត្ត ។

អ្នកសិក្សាត្រូវមានគណនេយ្យភាពចំពោះខ្លួនឯង ដោយចូលរួមយ៉ាងសកម្មក្នុងការសិក្សា។ អ្នកសិក្សាអាចមានគណនេយ្យភាពចំពោះអ្នកសិក្សាដូចគ្នា ដោយគ្រាន់តែមានលទ្ធភាពក្នុងការបង្កើតឡើងវិញនូវខ្លឹមសារ និងប្រើប្រាស់នៅក្នុងស្ថានភាពជាក់ស្តែង ។

គណនេយ្យភាពគឺជាការសំយោគនូវរាល់គោលការណ៍ទាំងអស់ ។

**ចូរបំពេញនូវសកម្មភាព២ខាងក្រោម៖**

**សកម្មភាពទី ១**

**វត្ថុបំណង៖**

- កំណត់បាននូវបញ្ញត្តិនៃគោលការណ៍នីមួយៗក្នុងគោលការណ៍ទាំង១២ នៃរបៀបរៀនរបស់មនុស្សពេញវ័យ។

**សកម្មភាព៖**

បន្ទាប់ពីបានអាននូវគោលការណ៍ទាំង១២ សូមភ្ជាប់រវាងគោលការណ៍នៅខាងឆ្វេងទៅនឹងបញ្ញត្តិដែលត្រឹមត្រូវនៅខាងស្តាំ។ ប្រសិនបើអនុវត្តលំហាត់នេះជាមួយនឹងគ្រូឧទ្ទេសថ្មី ចូរបង្កើតប័ណ្ណពណ៌ក្រហមតូចៗនៃគោល

ការណ៍ទាំងនោះ និងប័ណ្ណពណ៌លឿងនៃការពណ៌នាដែលត្រូវផ្គូផ្គង។ អ្នកអាចពិនិត្យភាពត្រឹមត្រូវ នៃចម្លើយរំពឹងទុកនៅទំព័របន្ទាប់។ ហាមលួចមើលមុន!

**សកម្មភាពទី ២**

**វត្ថុបំណង៖**

- ប្រើប្រាស់គោលការណ៍ទាំង១២ នៃការសិក្សារបស់មនុស្សពេញវ័យនៅក្នុងការអនុវត្ត ។

**សកម្មភាព៖**

នៅក្នុងក្រុមដែលមានសមាជិកពី៤ទៅ៥នាក់ ចូរផ្ដល់នូវឧទាហរណ៍អំពីរបៀបដែលនឹងប្រើប្រាស់ គោលការណ៍ទាំង១២ នៅក្នុងថ្នាក់ ។ ចំនួនគោលការណ៍ដែលអ្នកនឹងត្រូវធ្វើអាស្រ័យទាំងស្រុងទៅនឹងចំនួនអ្នកចូលរួម៖

ក្រុម ១៖ ធ្វើកិច្ចការលើឧទាហរណ៍នៃគោលការណ៍ទី១ ដល់ទី៣

ក្រុម ២ ៖ ធ្វើកិច្ចការលើឧទាហរណ៍នៃគោលការណ៍ទី៤ ដល់ទី៦

ក្រុម ៣៖ ធ្វើកិច្ចការលើឧទាហរណ៍នៃគោលការណ៍ទី៧ ដល់ទី៩

ក្រុម ៤៖ ធ្វើកិច្ចការលើឧទាហរណ៍នៃគោលការណ៍ទី១០ ដល់ទី១២

នៅពេលដែលឧទាហរណ៍ត្រូវបានសរសេរនៅលើក្រដាសផ្ទាំងធំរួចរាល់ ចូរបិទបង្ហាញក្រដាសនោះនៅជញ្ជាំង ហើយអ្នកចូលរួមដើរមើលគ្រប់ផ្ទាំង អានឧទាហរណ៍ ផ្ដល់គំនិតបន្ថែម ឬសួរសំណួរ។ ក្រុមនីមួយៗចាត់សមាជិកម្នាក់ឈរជិតក្រដាសផ្ទាំងធំរបស់ក្រុមខ្លួនចាំឆ្លើយសំណួរ ឬសរសេរបន្ថែម។

**ការផ្គូផ្គងប័ណ្ណគោលការណ៍ទៅនឹងប័ណ្ណពណ៌នា**

| ប័ណ្ណគោលការណ៍ | | ប័ណ្ណពណ៌នា |
|---|---|---|
| ការវាយតម្លៃពីតម្រូវការ | | ការសិក្សាដោយមានការឆ្លុះបញ្ចាំង |
| | | ចិត្ត អារម្មណ៍ សាច់ដុំ និងចលនា |
| សុវត្ថិភាព | | សមត្ថភាពក្នុងការសួរគ្រូឧទ្ទេស |
| | | គរុសិស្សពិភាក្សាវែកញែកទៅវិញទៅមក |
| ទំនាក់ទំនងជិតស្និទ្ធ | | មិនមានការរើសអើងនៅពេលដែលផ្ដល់ចម្លើខុស |
| | | ធ្វើការតាមវិធីបីយ៉ាង៖ ពីគ្រូឧទ្ទេសទៅកាន់អ្នកសិក្សា ពីអ្នកសិក្សាទៅកាន់អ្នកសិក្សាខ្លួនឯង និងពីអ្នកសិក្សាម្នាក់ទៅកាន់អ្នកសិក្សាផ្សេងទៀត |
| លំដាប់លំដោយ និងការពង្រឹងការរៀន | | អាចជជែកវែកញែកជាមួយនឹងគ្រូឧទ្ទេស |
| | | សំយោគនូវគោលការណ៍ទាំងអស់ |
| ការអនុវត្ត | | មិនមែនជាអ្នកសិក្សាអកម្ម |
| | | បញ្ចូលទៅក្នុងការអនុវត្តនូវអ្វីដែលបានរៀន |
| ការគោរព | | កិច្ចការចាប់ផ្ដើមពីងាយទៅលំបាក |

| | | |
|---|---|---|
| | | មានការសិក្សាបែបសកម្ម |
| គំនិត អារម្មណ៍ និងសកម្មភាព | | អ្នកសិក្សាធ្វើសេចក្ដីសម្រេចចិត្តសម្រាប់ខ្លួនឯង |
| | | សិក្សាអំពីសេចក្ដីពិតនៅក្នុងខ្លួនរបស់គរុសិស្ស |
| ភាពឆ្លើយតបភ្លាមៗ | | គោរពចំពោះអ្នកគ្រប់គ្នា គ្រូឧទ្ទេស និងគរុសិស្ស |
| | | ការស្ដាប់ដោយមានគោលបំណងច្បាស់លាស់ |
| តួនាទីច្បាស់លាស់ | | បង្កើតបរិយាកាសស្វាគមន៍ |
| | | មានសុវត្ថិភាពក្នុងការសួរសំណួរ |
| ការងារជាក្រុម | | រួមចំណែកនៅក្នុងទំនួលខុសត្រូវ |
| | | ពិចារណាទៅលើមនុស្សទាំងអស់ |
| ជំរុញឱ្យមានការចូលរួម | | ធ្វើឱ្យប្រសើរឡើងនូវជំនឿចិត្ត |
| | | ធ្វើម្ដងហើយម្ដងទៀតតាមវិធីផ្សេងៗគ្នា |
| គណនេយ្យភាព | | ដំណើរការជាលំដាប់លំដោយ |

**ចម្លើយរំពឹងទុក៖**

| ប័ណ្ណគោលការណ៍ | ប័ណ្ណពណ៌នា |
|---|---|
| | សិក្សាអំពីសេចក្ដីពិតនៅក្នុងខ្លួនរបស់គរុសិស្ស |
| ការវាយតម្លៃពីតម្រូវការ | ការស្ដាប់ដោយមានគោលបំណងច្បាស់លាស់ |
| | មិនមានការរើសអើងនៅពេលដែលផ្ដល់ចម្លើយខុស |
| សុវត្ថិភាព | បង្កើតបរិយាកាសស្វាគមន៍ |
| | គោរពចំពោះអ្នកគ្រប់គ្នា គ្រូឧទ្ទេស និងគរុសិស្ស |
| ទំនាក់ទំនងជិតស្និទ្ធ | មានសុវត្ថិភាពក្នុងការសួរសំណួរ |
| | កិច្ចការចាប់ផ្ដើមពីភាពងាយទៅលំបាក |
| លំដាប់លំដោយ និងការពង្រឹងការរៀន | ធ្វើម្ដងហើយម្ដងទៀតតាមវិធីផ្សេងៗគ្នា |
| ការអនុវត្ត | ការសិក្សាដោយមានការឆ្លុះបញ្ចាំង |
| | ដំណើរការជាលំដាប់លំដោយ |
| ការគោរព | អ្នកសិក្សាធ្វើសេចក្ដីសម្រេចចិត្តសម្រាប់ខ្លួនឯង |
| | មានការសិក្សាបែបសកម្ម |
| | ចិត្ត អារម្មណ៍ សាច់ដុំ និងចលនា |
| គំនិត អារម្មណ៍ និងសកម្មភាព | ពិចារណាទៅលើមនុស្សទាំងអស់ |
| | បញ្ចូលទៅក្នុងការអនុវត្តនូវអ្វីដែលបានរៀន |
| ភាពឆ្លើយតបភ្លាមៗ | ធ្វើឱ្យប្រសើរឡើងនូវជំនឿចិត្ត |
| តួនាទីច្បាស់លាស់ | សមត្ថភាពក្នុងការសួរគ្រូឧទ្ទេស |

| | |
|---|---|
| | អាចជជែកវែកញែកជាមួយនឹងគ្រូឧទ្ទេស |
| | រួមចំណែកនៅក្នុងទំនួលខុសត្រូវ |
| ការងារជាក្រុម | គរុសិស្សពិភាក្សាវែកញែកទៅវិញទៅមក |
| ជំរុញឱ្យមានការចូលរួម | មិនមែនជាអ្នកសិក្សាអកម្ម |
| | មានការសិក្សាបែបសកម្ម |
| គណនេយ្យភាព | សំយោគនូវគោលការណ៍ទាំងអស់ |
| | ធ្វើការតាមវិធីបីយ៉ាង៖ ពីគ្រូឧទ្ទេសទៅកាន់អ្នកសិក្សា ពីអ្នកសិក្សាទៅកាន់អ្នកសិក្សាខ្លួនឯង និងពីអ្នកសិក្សាម្នាក់ទៅកាន់អ្នកសិក្សាផ្សេងទៀត |

**ពីរទំព័របន្ទាប់ទៀតនេះ ត្រូវបានទុកចន្លោះសម្រាប់អ្នកក្នុងការកត់ត្រានូវឧទាហរណ៍អំពីសកម្មភាពទី២ នៃគោលការណ៍ទាំង១២ នៃរបៀបរៀនរបស់មនុស្សពេញវ័យ។**

ទំព័រទី២សម្រាប់កត់ត្រា៖

**ឧទាហរណ៍មួយចំនួននៃគោលការណ៍ទាំង១២ នៅក្នុងការអនុវត្តៈ**

**១.ការវាយតម្លៃអំពីតម្រូវការៈ** គ្រូឧទ្ទេសគួរតែចំណាយពេលក្នុងម៉ោងបង្រៀនក្នុងការស្គាល់គរុសិស្ស។ ការជួបទំនាក់ទំនងនេះអាចធ្វើឡើងនៅពេលទំនេរក្នុងឆមាស ហើយគោលបំណងសំខាន់គឺស្វែងរកនូវអ្វីដែលអ្នកសិក្សាបានដឹងរួចហើយ អ្វីដែលជាបទពិសោធ និងអ្វីដែលមានអត្ថប្រយោជន៍។

**២.សុវត្ថិភាពៈ** គ្រូឧទ្ទេសអាចបង្កើតនូវសុវត្ថិភាពដោយចែករំលែកនូវចំណេះដឹង បំណិន និងឥរិយាបថចំពោះការបង្រៀន។ វិធីមួយទៀតក្នុងការបង្កើតសុវត្ថិភាពគឺជាការបង្កើតវិន័យសម្រាប់ថ្នាក់រៀន ហើយត្រូវអនុវត្តវិន័យទាំងនោះជាមួយគ្នា។ ប្រសិនបើគ្រូឧទ្ទេសធ្វើខុស ឬយល់ខុសលើអ្វីមួយ ចូរសារភាពចំពោះភាពខុសឆ្គងនោះ ហើយការធ្វើបៀបនេះ អ្នកសិក្សានឹងមានអារម្មណ៍ថា វាមិនមានអ្វីខុសទេក្នុងការរៀនតាមរយៈការធ្វើឱ្យមានកំហុស។ គ្រូត្រូវធានាឱ្យបានថា មិនមានសិស្សណាម្នាក់សើចចំអកឱ្យសិស្សម្នាក់ទៀត ដោយសារតែការធ្វើឱ្យមានកំហុសឡើយ។

គ្រូឧទ្ទេសមិនត្រូវគិតពីអ្វីដែលអ្នកសិក្សាចូលចិត្ត ឬមិនចូលចិត្តទេ។ ការគោរពចំពោះអ្នកសិក្សាត្រូវតែរក្សាជាដរាប បើមិនដូច្នេះទេនឹងបង្កើតឱ្យមាននូវអតុល្យភាពនៃអំណាច ។

**៤.លំដាប់លំដោយ និងការពង្រឹងការរៀនៈ** គ្រូឧទ្ទេសមិនគួរធ្វើឱ្យកិច្ចការមានភាពលំបាកពេកសម្រាប់អ្នកសិក្សា ដូច្នេះត្រូវចាប់ផ្ដើមជាមួយនឹងអ្វីដែលអ្នកសិក្សាដឹងរួចហើយអំពីប្រធានបទ ហើយកសាងបន្ថែមទៀតចំពោះចំណេះដឹងដែលមានស្រាប់នោះ។ អ្នកសិក្សាគួរតែគិតថា តើអ្នកមានអារម្មណ៍ដូចម្ដេចចំពោះកិច្ចការនេះ? តើអ្នកគ្រប់គ្នាយល់ច្បាស់ដែរឬទេ? សម្រាប់ការពង្រឹងការរៀន គ្រូឧទ្ទេសត្រូវការនិយាយហើយនិយាយទៀត និយាយច្រើនរបៀបអំពីបំណិនជាក់ស្ដែង និងឥរិយាបថទៅតាមវិធីដែលគួរឱ្យចាប់អារម្មណ៍ ។

**៥.ការអនុវត្តៈ** គ្រូឧទ្ទេសអាចប្រើប្រាស់ករណីសិក្សា និងអញ្ជើញអ្នកសិក្សាធ្វើការរៀបរាប់ វិភាគ ប្រើប្រាស់ ហើយយកទៅអនុវត្ត។ ឧទាហរណ៍ៈ ចែករំលែកនូវករណីសិក្សាអំពីរបៀប "កំណត់ភាពផ្សេងៗគ្នារបស់សិស្ស" នៅក្នុងកិច្ចតែងការបង្រៀន រួចហើយឱ្យអ្នកសិក្សាអធិប្បាយអំពីអ្វីដែលកំពុងតែកើតមានឡើងនៅក្នុងថ្នាក់រៀន ដើម្បីវិភាគចំណុចនេះ ហើយអនុវត្តដោយប្រើប្រាស់ករណីសិក្សាផ្សេងមួយទៀត ។

**៦.ការគោរព (អ្នកសិក្សាដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្ត)ៈ** នៅក្នុងមេរៀនផ្ដល់ដល់អ្នកសិក្សានូវជម្រើស ដែលពួកគេចង់អនុវត្តនូវអ្វីដែលគេបានរៀន ដូចជាតាមរយៈការដើរតួ ការស្រាវជ្រាវ ការធ្វើបទបង្ហាញដល់អ្នកសិក្សាផ្សេងទៀត និងការសរសេរករណីសិក្សាដែលពាក់ព័ន្ធ។ល។

**៧.គំនិត អារម្មណ៍ និងសកម្មភាពៈ** ពាក់ព័ន្ធទៅនឹងការបង្កើតនូវបទពិសោធនៃការសិក្សា ដែលពាក់ព័ន្ធទៅនឹងចំណុចទាំងបីនេះ។ ធម្មតាការសិក្សាគឺគ្រាន់តែជាការរៀនអំពីគំនិត បញ្ញត្តិ និងការពិត។ ឧទាហរណ៍ គឺត្រូវបង្ហាញសម្ភារសិក្សាដែលមិនមានការពិតពេក (គំនិត) ដែលធ្វើឱ្យអ្នកសិក្សាភ័យខ្លាច ការវាស់ស្ទង់នូវគំនិតរបស់អ្នកសិក្សា នៅពេលដែលបង្ហាញអំពីឱកាសក្នុងការសិក្សា និងរៀបចំសកម្មភាពរៀនតាមរបៀបដែលធ្វើឱ្យក្លាយទៅជាបទពិសោធដ៏មានអត្ថន័យ។ នេះបង្ហាញថាគ្រូកំពុងតែប្រើប្រាស់អំណាចរបស់ខ្លួនបានប្រសើរ។

**៨.ភាពឆ្លើយតបភ្លាមៗៈ** ចំណុចនេះមិនមែនជាការដោះស្រាយភ្លាមៗ ដូចចំណងជើងបានលើកឡើងនោះទេ។ ឧទាហរណ៍ៈ បំបែកមេរៀនមួយឱ្យខ្លីៗហើយពង្រាយក្នុងអំឡុងពេលពីរទៅបីថ្ងៃជាជាងការធ្វើផែនការបង្រៀនមេរៀនមួយឱ្យចប់។ នៅក្នុងអំឡុងពេលនោះអ្នកសិក្សាអាចសាកល្បងនូវការសិក្សាបែបថ្មី ហើយគិតថា តើមានប្រយោជន៍សម្រាប់ពួកគេនាពេលបច្ចុប្បន្ន និងអនាគតដែរឬទេ។

**៩.តួនាទីច្បាស់លាស់៖** តួនាទីរវាងគ្រូឧទ្ទេស និងអ្នកសិក្សាត្រូវបានបែងចែកយ៉ាងច្បាស់លាស់ ដោយគ្រូជាអ្នកសម្របសម្រួល និងអ្នកសិក្សាជាអ្នកចូលរួមស្វែងរកនូវអ្វីជាចំណុចខ្លាំង ចែករំលែកនូវចំណេះដឹង និងបំណិន។ អ្នកសិក្សាអាចប្រើប្រាស់ទូរស័ព្ទ (smart phone) ស្វែងរករូបមន្តផ្សេងៗ។ល។ នៅពេលនោះនឹងមានសមភាពរវាងអ្នកសិក្សា និងគ្រូឧទ្ទេស។ ម្យ៉ាងវិញទៀតវាក៏ជារបៀបដែលអ្នកសិក្សាប្រើប្រាស់ឱ្យមានប្រយោជន៍នូវការសិក្សាបែបថ្មី និងស្របជាមួយនឹងបរិបទផ្ទាល់ខ្លួនរបស់ពួកគេ។

**១០.ការងារក្រុម៖** ឧទាហរណ៍មួយនៅក្នុងចំណុចនេះគឺការអនុញ្ញាតឱ្យអ្នកសិក្សាធ្វើការជាក្រុម ដែលសមាជិកក្រុមគឺជាមិត្តរួមថ្នាក់ (ពួកគេអាចជ្រើសរើសបានចំពោះអ្នកណាដែលពួកគេចង់ធ្វើការជាមួយ) ហើយទទួលខុសត្រូវរួមគ្នាក្នុងការសិក្សា។ ពួកគេគួរតែមានអារម្មណ៍ជឿជាក់ និងមានផាសុកភាពគ្រប់គ្រាន់ក្នុងការជជែកវែកញែកក្នុងចំណោមមិត្តភក្តិរបស់ពួកគេនៅក្នុងក្រុម និងពង្រីកនូវការសិក្សារបស់ពួកគេទាំងអស់គ្នា ។

**១១.ការជំរុញឱ្យមានការចូលរួម៖** ឧទាហរណ៍មួយនៃចំណុចនេះគឺគ្រូឧទ្ទេសអនុញ្ញាតឱ្យអ្នកសិក្សាអាចធ្វើការជាក្រុម ឬជាដៃគូ ក្នុងការស្វែងរកដំណោះស្រាយចំពោះសំណួរដែលត្រូវបានសួរ។ ពួកគេចូលរួមយ៉ាងសកម្មនៅក្នុងការសិក្សា។ គ្រូឧទ្ទេសមិនត្រូវឈរបង្រៀនតែម្នាក់ឯងរហូតនោះទេ ។

**១២. គណនេយ្យភាព៖** គឺជាសំយោគនៃគោលការណ៍ទាំង១១ខាងលើ ហើយរបៀបរៀនរបស់មនុស្សពេញវ័យត្រូវតែមានគណនេយ្យភាព ដែលត្រូវដំណើរការតាមរយៈបីរបៀបដូចបានពន្យល់ខាងលើ។ ឧទាហរណ៍ដ៏ល្អមួយគឺអ្នកសិក្សាទទួលខុសត្រូវដើម្បីក្លាយជាគ្រូបរិយាបន្ន ហើយអនុវត្តនូវវិធីបង្រៀនការអប់រំបរិយាបន្ន ។

## ប្រធានបទទី ២៖ ការអនុវត្តវិធីបង្រៀនការអប់រំបរិយាបន្ន

ប្រធានបទនេះពាក់ព័ន្ធទៅនឹងរបៀបរៀនរបស់មនុស្សពេញវ័យ និងប្រសិនបើគោលការណ៍ទាំង១២ ដែលរៀបរាប់ខាងលើត្រូវបានអនុវត្ត វាមានដំណើរស្របគ្នាក្នុងការធានាថាគ្រូឧទ្ទេសជាគ្រូបរិយាបន្ន ហើយប្រើប្រាស់នូវវិធីបង្រៀនការអប់រំបរិយាបន្ន ។

គោលបំណងនៃលំហាត់បន្ទាប់ គឺសម្រាប់គ្រូឧទ្ទេសក្នុងការស្វែងយល់ដោយខ្លួនឯងថាតើឥរិយាបថការបង្រៀន ក៏ដូចជាការកំណត់នូវលក្ខណៈសម្បត្តិថាខ្លួនមានបរិយាបន្នកម្រិតណា ។

ក្នុងទំព័របន្ទាប់មានលំហាត់មួយ[7] ដែលជាបញ្ជីសំណួរ សម្រាប់អ្នកក្នុងការបំពេញ ។

**សេចក្តីណែនាំក្នុងការបំពេញបញ្ជីសំណួរមានដូចតទៅ៖**

- ឆ្លើយសំណួរទាំងអស់ដោយស្មោះត្រង់តាមតែអាចធ្វើបាន ដោយសារនេះជាលំហាត់សម្រាប់បុគ្គលផ្ទាល់ខ្លួន ។ ចម្លើយរបស់អ្នកនឹងមិនត្រូវបានមើលដោយអ្នកណាម្នាក់ឡើយ។ អ្នកត្រូវតែគូសសញ្ញា (√) នៅលើចម្លើយដែលត្រឹមត្រូវទៅនឹងការអនុវត្តរបស់អ្នក ក្នុងនាមជាគ្រូឧទ្ទេស។
- អ្នកអាចពិភាក្សាចម្លើយរបស់អ្នកជាមួយនឹងគ្រូឧទ្ទេសផ្សេងទៀត ដែលបានបំពេញបញ្ជីសំណួរដូចគ្នា ដើម្បីស្វែងរកចម្លើយត្រឹមត្រូវ ដែលមានចម្លើយ "បាទ/ចាស" ច្រើនបំផុត។
- ចំនួននៃការឆ្លើយ "បាទ/ចាស" កាន់តែច្រើន បានន័យថាអ្នកមានកម្រិតបរិយាបន្នកាន់តែប្រសើរ។

**តើខ្ញុំមានវិធីបង្រៀនការអប់រំបរិយាបន្ន ក្នុងការបង្រៀនគ្រូដែរឬទេ?**

ចូរបំពេញបញ្ជីសំណួរនៅទំព័របន្ទាប់ ។

[7] លំហាត់ដកស្រង់ចេញពី Sandrine Bohan-Jacquot (2014) 'ការបណ្តុះបណ្តាលគ្រូនៅ South Sudan៖ ម៉ូឌុលសម្រាប់ផ្នែកសិក្សាអាជីព ស្តីអំពីការអប់រំបរិយាបន្ន' Norad, Stromme Foundation, Ministry of Education, South Sudan and Light for the World.

ដោយ Jennifer Spratt និង Lani Florian[8]

| | សំណួរ | បាទ/ចាស | ទេ | ខ្ញុំមិនដឹង |
|---|---|---|---|---|
| ១. | តើខ្ញុំស្វាគមន៍អ្នកសិក្សាគ្រប់គ្នានៅក្នុងថ្នាក់ ដោយមិនគិតអំពីភេទ ស្ថានភាពសង្គម សេដ្ឋកិច្ច ពិការភាព ជាតិសាសន៍ ឬសាសនាដែរឬទេ? | | | |
| ២. | តើខ្ញុំរៀបចំថ្នាក់រៀន ដែលចូលរៀនបានសម្រាប់សិស្សទាំងអស់ និងបង្ហាញនូវកិច្ចការឬព័ត៌មានដល់អ្នកសិក្សាដែរឬទេ? | | | |
| ៣. | តើខ្ញុំត្រូវយល់ព្រមក្នុងការផ្លាស់ប្តូររបៀបអង្គុយ ដើម្បីឱ្យសិស្សដែលជិះរទេះអាចចូលរួមរៀនបានដែរឬទេ? | | | |
| ៤. | តើខ្ញុំបានបង្កើតវិន័យនៅក្នុងថ្នាក់ដោយមានការចូលរួមដែរឬទេ? ឧ. ការគោរពគ្នាទៅវិញទៅមក មិនបំពានគ្នា ស្តាប់គ្នាទៅវិញទៅមក គ្មានការដាក់ទណ្ឌកម្ម ។ល។ | | | |
| ៥. | តើខ្ញុំប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនដែរឬទេ? | | | |
| ៦. | តើខ្ញុំអាចរៀបរាប់វិធីបង្រៀនខាងលើយ៉ាងតិចបីដែរឬទេ? | | | |
| ៧. | តើខ្ញុំរកឃើញតម្រូវការខុសៗគ្នា របស់អ្នកសិក្សានៅក្នុងថ្នាក់ និងរបៀបដែលគេរៀនបានប្រសើរបំផុតដែរឬទេ? | | | |
| ៨. | តើខ្ញុំប្រើសំឡេង រូបភាព ការស្ទាប និងសញ្ញា ដើម្បីបំពេញនូវតម្រូវការរៀនផ្សេងៗគ្នារបស់សិស្សដែរឬទេ? | | | |
| ៩. | តើខ្ញុំបន្តការរៀនសូត្រដោយខ្លួនឯង តាមរយៈការស្រាវជ្រាវលើមុខវិជ្ជាដែលខ្ញុំបង្រៀន ការអានសៀវភៅឬតាមអ៊ីនធឺណែត ឬទទួលយកឱកាសហ្វឹកហ្វឺនបន្តទៀតដែរឬទេ? | | | |

[8] Jennifer Spratt and Lani Florian (2013) *ការប្រើប្រាស់នូវគោលការណ៍ នៃវិធីបង្រៀនការអប់រំបរិយាបន្ននៅក្នុងការផ្តួចផ្តើមការអប់រំគ្រូ៖ ចេញពីមុខវិជ្ជាមូលដ្ឋាន ទៅកេសកម្មភាពក្នុងថ្នាក់រៀន* Revista de Investigación en Educación, nº 11 (3), 2013, pp. 133-140

**យុទ្ធវិធីបង្រៀនការអប់រំបរិយាបន្នដែលនាំឱ្យមានគ្រូបរិយាបន្ន៖**

**យុទ្ធវិធីទី ១៖ ការយល់ដឹងអំពីការសិក្សា**

យុទ្ធវិធីនេះផ្ដោតទៅលើគោលការណ៍ ដែលភាពខុសគ្នាត្រូវតែយកចិត្តទុកដាក់សម្រាប់រាល់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍរបស់មនុស្សនិងការសិក្សា។ គោលការណ៍នេះប្រឈមទៅនឹងការសន្មតជាមូលដ្ឋាន ដែលមានការបែងចែកស្មើភាពគ្នានៃបញ្ញា។

- ផ្ដោតទៅលើបំណិន គុណតម្លៃ និងឥរិយាបថ

កាលពីមុនកម្មវិធីបណ្ដុះបណ្ដាលគរុសិស្សនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រទេសផ្សេងទៀតដែរ *"ផ្ដោតសំខាន់ទៅលើចំណេះដឹងជាងបំណិន គុណតម្លៃ និងឥរិយាបថ"* អង្គការ*UNICEF* [9]។

គ្រូឧទ្ទេសនៅសាលាគរុកោសល្យរាជធានី ខេត្ត បានលើកឡើងថា កម្មវិធីបណ្ដុះបណ្ដាលមានខ្លឹមសារច្រើនឯចំនួនម៉ោងដែលផ្ដល់ឱ្យមានតិច ធ្វើឱ្យមានការលំបាកខ្លាំងក្នុងការអនុវត្ត។ ចំណុចនេះគឺជាបញ្ហាសំខាន់ក្នុងការអនុវត្តកម្មវិធីអប់រំបរិយាបន្ន ជាពិសេសគរុសិស្សមិនមានឱកាសគ្រប់គ្រាន់ក្នុងការអនុវត្តនូវចំណេះដឹងដែលបានទទួល ។

- គ្រូឧទ្ទេសជាគំរូ

កត្តាដែលសំខាន់មួយទៀតសម្រាប់គ្រូឧទ្ទេសក្នុងការចងចាំគឺ ពួកគេមានឥទ្ធិពលដ៏ធំធេងចំពោះអ្នកដែលមានអនាគតជាគ្រូបង្រៀន ហើយនឹងប្រែក្លាយជាគ្រូបរិយាបន្នកម្រិតណា។ ដូច Koughan et al[10] ពោលថា តួនាទីជាគ្រូបង្រៀននិងជាអ្នកអប់រំ គឺមានភាពពិសេសខុសគេ ហើយ*"វិធីដែលគ្រូនិងអ្នកអប់រំ ធ្វើជាគំរូក្នុងការលើកកម្ពស់តាមរបៀបណាមួយនៃការសិក្សា អាចជាកត្តាសំខាន់ក្នុងការសម្រេចអាកប្បកិរិយារបស់គ្រូ"*។

**យុទ្ធវិធីទី២៖ យុត្តិធម៌សង្គម**

យុទ្ធ**វិធី**នេះផ្ដោតសេចក្ដីសង្ឃឹមទៅលើគ្រូដែលទទួលខុសត្រូវក្នុងការសិក្សា របស់កុមារទាំងអស់នៅក្នុងថ្នាក់រៀន។ យុទ្ធវិធីនេះធ្វើការបង្វែរពីជំនឿ គំនិតដែលថាកុមារមានបញ្ហាក្នុងការសិក្សាទៅជាគំនិតដែលថាគ្រូត្រូវស្វែងរកវិធីផ្សេងៗក្នុងការបង្រៀនដែលអនុញ្ញាតឱ្យកុមារទាំងអស់នៅក្នុងថ្នាក់រៀនអាចរៀនបាន។

- ការរៀនសូត្រក្នុងការធ្វើការងារជាមួយនឹងភាពចម្រុះ

ក្នុងនាមជាគ្រូឧទ្ទេស ក្នុងការបណ្ដុះបណ្ដាលគរុសិស្សស្ដីពីការអប់រំបរិយាបន្ន វាមានសារៈសំខាន់ ក្នុងការស្វែងយល់ និងអនុវត្តវិធីបង្រៀនការអប់រំបរិយាបន្ន។ ការស្រាវជ្រាវរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ (**OECD**)[11] បានរកឃើញថាមានចំណេះដឹងយ៉ាងតិចតួចគួរឱ្យភ្ញាក់ផ្អើល ដែលគ្រូឧទ្ទេសខ្លួនឯងបានត្រៀមសម្រាប់ដោះស្រាយនឹងភាពចម្រុះ។ នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាក្នុងប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត ការត្រៀមរៀបចំសម្រាប់គ្រូឧទ្ទេសគឺភាគច្រើន តាមរយៈការបណ្ដុះបណ្ដាលនៅពេលដែលកម្មវិធីសិក្សាថ្មី ត្រូវបានអភិវឌ្ឍឡើង។ ការបណ្ដុះបណ្ដាលគរុសិស្សមិនបានចាប់ផ្ដើមក្នុងស្ថានភាពបែបបរិយាបន្នទេ។ ការអប់រំបរិយាបន្នគឺជាការបន្ថែមនូវជំពូក ឬម៉ូឌុលនៅក្នុងកម្មវិធីទាំងមូល។

---

[9] UNICEF (2014) គ្រូ ការបញ្ចូលគ្នា គរុកោសល្យ និងការបង្រៀនបែបសិស្សជមជ្ឈមណ្ឌល៖ *Webinar 12* – សៀវភៅបច្ចេកទេសអម ́NY, USA *p*g. 32

[10] Korthagen, F., Loughran, J. and Lunenberg, M. (2005) ការបង្រៀនគ្រូ៖ ការសិក្សាក្នុងជំនាញរបស់អ្នកអប់រំគ្រូ Teaching and Teacher Education, 21 (2), 107-115

[11] OECD (2010) អប់រំគ្រូសម្រាប់ភាពចម្រុះ៖ ការជួបប្រទះនូវបញ្ហាប្រឈម Paris OECD CERI, http://www.oecd.org/document/38/0,3343,en_2649_35845581_44572006_1_1_1_1, 00.html Last accessed 30/03/2010

**យុទ្ធវិធីទី ៣៖ ការក្លាយខ្លួនទៅជាអ្នកអាជីពដែលសកម្ម**

យុទ្ធវិធីនេះតម្រូវថា គ្រូស្វែងរកមធ្យោបាយជាបន្តបន្ទាប់ក្នុងការគាំទ្រការសិក្សារបស់កុមារទាំងអស់នៅក្នុងថ្នាក់រៀន។ គោលការណ៍គន្លឹះនៃយុទ្ធវិធីនេះ ហាក់ដូចជាប្លែកពីការបង្រៀនថ្នាក់ធម្មតា និងថ្នាក់អប់រំពិសេស។ យុទ្ធវិធីនេះគ្របដណ្តប់ទិដ្ឋភាពដែលអ្នកអាជីពធ្វើការជាមួយគ្នា ក្នុងគោលបំណងបំពេញតម្រូវការកុមារនៅក្នុងថ្នាក់រៀនណាមួយ។ វិធីសាស្ត្របន្តបន្ទាប់នេះ គាំទ្រដល់យុទ្ធវិធីទាំងបីដែលបានរៀបរាប់ខាងលើ។ វិធីសំខាន់មួយគឺការបង្រៀនតាមកម្មវិធីអប់រំបរិយាបន្ន វិធីបង្រៀនការអប់រំបរិយាបន្ន ហើយការធ្វើដូច្នេះ គ្រូឧទ្ទេសត្រូវដឹងអំពីភាពចម្រុះនៃតម្រូវការរបស់គរុសិស្ស ។ ចំណុចនេះត្រូវបានបង្ហាញដោយ **Bondy et al**[12] ដែលសង្កត់ធ្ងន់ថា *"គ្រូឧទ្ទេសត្រូវតែប្រើវិធីចម្រុះក្នុងការបង្រៀនគរុសិស្ស"*។

- ការសិក្សាបែបពិសោធ

គ្រូឧទ្ទេសមួយចំនួនមានឱកាសចូលរួមក្នុងការអភិវឌ្ឍកម្មវិធីសិក្សា ហើយទោះបីជាមានឱកាសសម្រាប់គ្រូឧទ្ទេសក្នុងការរៀនតាមរយៈបទពិសោធ ឱកាសនេះកម្រនឹងទទួលយកទៅអនុវត្ត[13]។ មានគ្រូឧទ្ទេសនៅតាមអង្គការក្នុងប្រទេសកម្ពុជា ដែលបានបង្រៀនកុមារពិការ ហើយមានការរីកចម្រើនក្លាយទៅជាគ្រូឧទ្ទេសនៅក្នុងអង្គការទាំងនោះ។ ទោះបីជាយ៉ាងណា បទពិសោធនេះមានតែនៅក្នុងថ្នាក់សមាហរណកម្ម ហើយមានតម្រូវការជាបន្តបន្ទាប់សម្រាប់គ្រូឧទ្ទេស ក្នុងការលើកកម្ពស់ជំនាញអប់រំមូលដ្ឋានក្នុងការអប់រំបរិយាបន្ន ដូចបានពន្យល់ខាងលើក្នុងការបន្ថែមទៅលើកម្មវិធីសិក្សាទាំងមូល។ **Forlin**[14] **(ទំព័រ២៧)** ពោលថា *"គ្រូឧទ្ទេសក៏ត្រូវការលើកកម្ពស់ជំនាញ មុនពេលបណ្តុះបណ្តាលគរុសិស្សឱ្យក្លាយជាគ្រូអប់រំបរិយាបន្ន"*។

- ការសិក្សាផ្តោតលើសកម្មភាព

នៅក្នុងផ្នែកដែលនិយាយអំពីរបៀបរៀនរបស់មនុស្សពេញវ័យ គោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំង១២ គឺ "ការអនុវត្ត **(Praxis)**" ដែលមានន័យថាសកម្មភាពណាមួយដែលធ្វើឡើងដោយមានការឆ្លុះបញ្ចាំងអំពីតម្រូវការ។ **Whilst Shart**[15] **(ទំព័រ១០៩)** សង្កត់ធ្ងន់ថាការអនុវត្តដែលមានលក្ខណៈឆ្លុះបញ្ចាំងមានន័យថា *គ្រូឧទ្ទេសត្រូវអនុវត្តនូវអ្វីដែលពួកគេបង្រៀន*។ ឯកសារស្តីពីការអប់រំបរិយាបន្ននេះមានមេរៀនមួយនិយាយអំពីការសិក្សាផ្តោតលើសកម្មភាព។ មុនពេលបង្រៀនគ្រូឧទ្ទេសត្រូវរៀបចំសកម្មភាពសិក្សាតាមបែបស្រាវជ្រាវដែលគ្រូឧទ្ទេសត្រូវជួបជាមួយនឹងគ្រូឧទ្ទេសផ្សេងទៀតជាទៀងទាត់ ដើម្បីឆ្លុះបញ្ចាំង និងធ្វើផែនការបង្រៀន។ ការធ្វើដូច្នេះ គ្រូឧទ្ទេសក្លាយជាគំរូសម្រាប់អ្នកផ្សេងៗទៀត ។

---

[12] Bondy E., Ross, D., Adams, A., Nowak, R., Brownell, M., Hoppey, D., Kuhel, K., McCallum, C. and Stafford, L. (2007) ទ្រឹស្តីនៃការអប់រំបុគ្គល និងការរៀនដើម្បីបង្រៀន៖ ការអប់រំគ្រូ និងការអប់រំពិសេស The Journal of the Teacher Education Division of the Council for Exceptional Children, 30, 67

[13] ពំនោលរបស់គ្រូឧទ្ទេសម្នាក់នៅសាលាគរុកោសល្យ និងវិក្រឹតការខេត្ត ក្នុងអំឡុងពេលអង្កេតដែលធ្វើឡើងដោយ Kiran Dattani Pitt នាខេត្តកណ្តាល និងកំពង់ចាម ថ្ងៃទី ១៧ និង១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

[14] Forlin (2013) ការផ្លាស់ប្តូរនូវទម្រង់ និងគោលដៅសម្រាប់អនាគត សម្រាប់ការអនុវត្តការអប់រំបរិយាបន្នក្នុងប្រទេសកំពុងអភិវឌ្ឍ Asian Journal of Inclusive Education Vol. 1 No. 2 pps 19-30.

[15] Sharma, U. (2010) ការប្រើប្រាស់នូវការអនុវត្តបែបឆ្លុះបញ្ចាំងសម្រាប់ត្រៀមរៀបចំគ្រូមុនចូលបង្រៀន ក្នុងថ្នាក់បរិយាបន្ន។ នៅក្នុង Forlin, C. (ed.) (2010) ការអប់រំគ្រូសម្រាប់ការអប់រំបរិយាបន្ន ។ ការផ្លាស់ប្តូរនូវទម្រង់ និងវិធីសាស្ត្រទំនើប London: Routledge

## ប្រធានបទទី៣៖ ការប្រើប្រាស់វិធីបង្រៀនការអប់រំបរិយាបន្នដោយផ្ដោតសំខាន់លើការអនុវត្តជាក់ស្ដែង

ប្រធានបទនេះមានគោលបំណងបង្ហាញពីបញ្ញត្តិនៃការសិក្សា តាមបែបអនុវត្តជាក់ស្ដែងដែលត្រូវបានចាត់ទុកជាមធ្យោបាយមួយ សម្រាប់គាំទ្រដល់ដំណើរការបង្រៀន និងរៀន របស់គរុសិស្ស ។

**ដើម្បីយល់បញ្ញត្តិ នេះ ចូរបំពេញនូវលំហាត់ខាងក្រោម៖**

**សកម្មភាពបង្រៀន៖**

**ពិភាក្សាក្រុម៖**

"ហេតុអ្វីបានជាចាំបាច់បង្កើតនូវគំរូការអប់រំបរិយាបន្ននៅពេលបង្រៀនមេរៀននេះ?"

**សំណួរខាងក្រោមអាចជួយអ្នកក្នុងការគិត៖**

- តើមនុស្សពេញវ័យរៀនដូចម្ដេច?
- តើយើងរៀនបានប្រសើរជាងមុនតាមរយៈការអនុវត្ត ឬតាមរយៈឮគ្រូនិយាយ?
- តើគ្រូបង្រៀនតាមរបៀបដែលគេបានរៀននៅសាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត? ឬមុខវិជ្ជាដែលបង្រៀនដោយអង្គការក្រៅរដ្ឋាភិបាល? ឬតាមរបៀបដែលគេឃើញគ្រូជំនាន់មុនបង្រៀន?

**ចម្លើយរំពឹងទុក៖**

ចម្លើយមួយចំនួនសម្រាប់សំណួរ "ហេតុអ្វីបានជាចាំបាច់បង្កើតនូវគំរូការអប់រំបរិយាបន្ននៅពេលបង្រៀនមេរៀននេះ?"

- ពីព្រោះវាជាការចាំបាច់ក្នុងការបង្រៀនមេរៀននេះតាមរបៀបអប់រំបរិយាបន្ន ដោយសារតែគ្មានអ្នកណាម្នាក់អាចជួយផ្ដល់យោបល់ពីរបៀបបង្រៀនការអប់រំបរិយាបន្ន។
- ពីព្រោះមនុស្សចងចាំបានប្រសើរនៅពេលអនុវត្ត។ (សូមមើលសាជីនៃការរៀន)

# សាជីនៃការរៀន

ដោយ Edgar Dale[16]




- ពីព្រោះគ្រូបង្រៀនតាមរបៀបដែលគាត់ធ្លាប់រៀនពីមុនជាពិសេសគ្រូចេញថ្មី។ ប្រសិនបើពួកគេមិនមានមូលដ្ឋានគ្រឹះក្នុងការបណ្តុះបណ្តាលរឹងមាំទេ ពួកគេនឹងមិនអនុវត្តនូវការបង្រៀនអប់រំបរិយាបន្ន។
- ពីព្រោះវាមានភាពគួរឱ្យចាប់អារម្មណ៍ និងសប្បាយរីករាយ។
- ពីព្រោះតែគ្រឹះស្ថានបណ្តុះបណ្តាល មានទំនួលខុសត្រូវក្នុងការបណ្តុះបណ្តាលគ្រូ ដើម្បីសម្រេចបាននូវគុណភាពអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។

[16] ដកស្រង់ចេញពី Edgar Dales *Audio-Visual Materials in Teaching.*

**លំហាត់ជាបុគ្គល៖**

ចូរសរសេរចម្លើយនៅក្នុងចន្លោះដែលបានផ្តល់ឱ្យសម្រាប់សំណួរខាងក្រោម៖

១. តើអ្វីខ្លះដែលអ្នកបានរៀនពីសៀវភៅអមនេះ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

២. ចូរសរសេរខ្លឹមសារដែលអ្នកមិនទាន់បានយល់ច្បាស់លាស់។ ចូរស្វែងរកព័ត៌មានបន្ថែមទៀតអំពីចំណុចទាំងនេះដោយខ្លួនឯង (នេះគឺជាអ្នកអាជីពដែលសកម្ម)។

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៣. តើអ្នកនឹងយកខ្លឹមសារ និងសកម្មភាពណាខ្លះដែលអ្នកបានរៀនទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាលគរុសិស្ស?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

## សន្និដ្ឋាន

គ្រូឧទ្ទេសនឹងយល់អំពីមូលហេតុដែលនៅពីក្រោយការប្រើប្រាស់គរុកោសល្យ និងការសិក្សាបែបអនុវត្តជាក់ស្តែង នៅក្នុងឯកសារការអប់រំបរិយាបន្នដែលបានកែលម្អតាមរយៈសៀវភៅអមនេះ។ ដោយទទួលបាននូវការយល់ដឹងអំពីរបៀបរៀនរបស់មនុស្សពេញវ័យ វានឹងជួយក្នុងការបណ្តុះបណ្តាលគរុសិស្សតាមរបៀបទទួលស្គាល់ថាពួកគេជាមនុស្សពេញវ័យ ដែលទទួលបានការសិក្សាប្រសើរជាងមុននៅពេលដែលពួកគេត្រូវបានអនុញ្ញាតឱ្យទទួលខុសត្រូវក្នុងការសិក្សា។

"គ្រូមិនសូវល្អ ប្រាប់

គ្រូល្អ ពន្យល់

គ្រូដ៏ល្អ បង្ហាញ

គ្រូដ៏អស្ចារ្យ ជំរុញ"

*ដោយ William Arthur Ward*

# ឯកសារយោង៖


Bohan-Jacquot, S. (2014) 'South Sudan Teacher Training Education: Training Module for Professional Studies Unit on Inclusive Education' Norad, Stromme Foundation, Ministry of Education, South Sudan and Light for the World.

Bondy E., Ross, D., Adams, A., Nowak, R., Brownell, M., Hoppey, D., Kuhel, K., McCallum, C. and Stafford, L. (2007) Personal Epistemologies and Learning to Teach. Teacher Education and Special Education: The Journal of the Teacher Education Division of the Council for Exceptional Children, 30, 67

Jennifer Spratt and Lani Florian (2013) *Applying the Principles of Inclusive Pedagogy in Initial Teacher Education: from University Based Course to Classroom Action* Revista de Investigación en Educación, nº 11 (3), 2013, pp. 133-140

Forlin (2013) *'Changing Paradigms and Future Directions for Implementing Inclusive Education in Developing Countries.* Asian Journal of Inclusive Education Vol. 1 No. 2 pps 19-30.

Knowles, M. (2010) 'Adult Learning Processes: Pedagogy and Andragogy' Taylor and Francis online resource.

Korthagen, F., Loughran, J. and Lunenberg, M. (2005) Teaching teachers: Studies into the expertise of teacher educators. Teaching and Teacher Education, 21 (2), 107-115

OECD (2010) Educating Teachers for Diversity. Meeting the Challenge. Paris: OECD CERI.

Sharma, U. (2010) Using reflective practices for the preparation of pre-service teachers for inclusive classrooms. In Forlin, C. (ed.) (2010) Teacher Education for Inclusion. Changing Paradigms and Innovative Approaches. London: Routledge

UNICEF (2014) *'Teachers, Inclusive, Child Centred Teaching and Pedagogy: Webinar 12 – Companion Technical Booklet.'* NY, USA *pg*. 32

Vella, J. (2002) *Learning to Listen, Learning to Teach* Jossey-Bass: San Fransisco.

Wisconsin Union (undated online resource) 'What makes for Effective Adult Learning' Mini-course Instructor Resource

គាំទ្រថវិកាដោយអង្គការ UNICEF
គាំទ្របច្ចេកទេសដោយអង្គការគ្រួសារថ្មី